# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអធិដ្ឋានពេញមួយយប់នៅទេវវិទ្យាល័យ
# ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៨
## *ឲ្យយើងមានចិត្តស្មោះនឹងព្រះអម្ចាស់*

អត្ថបទទី១៖ ១ពង្សប្រ ២,១-៤.១០-១២
ដំណឹងល្អ៖ មក ៦,៧-១៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាឱកាសមួយសម្រាប់យើងទាំងអស់ ទោះបីយើងឆ្លើយតបការត្រាស់ហៅអស់ហើយ ទោះបីយើងកំពុងរិះគិត ទោះបីយើងមានជីវិតជាឪពុកម្ដាយ ជាលោកតាលោកយាយអស់ហើយ យើងត្រូវការយល់ថា យើងរៀងៗខ្លួនយើងទទួលខុសត្រូវនៅក្នុងការត្រាស់ហៅ។ យើងរៀងៗខ្លួន យើងទទួលតួនាទីមួយយ៉ាងសំខាន់ដើម្បីកសាងព្រះសហគមន៍ ដោយសារការត្រាស់ហៅមិនអាចធ្លាក់ពីលើដល់យុវជនយុវនារីណាម្នាក់ ប៉ុន្តែកើតឡើងនៅក្នុងជីវិតនៃព្រះសហគមន៍ កើតឡើងនៅក្នុងជីវិតគ្រួសារ កើតឡើងនៅក្នុងជីវិតមនុស្សម្នាក់ដែលចូលនៅក្នុងទំនាក់ទំនងជាមួយព្រះសហគមន៍ផង ជាមួយក្រុមគ្រួសារផង ជាមួយបងប្អូនផង ជាមួយគ្រីស្តបរិស័ទផ្សេងៗផង និងណែនាំឲ្យយើងទាំងអស់គ្នា យើងត្រូវការទទួលខុសត្រូវ ដោយអធិដ្ឋានផង ផ្ដល់សាក្សីភាព និងដើម្បីជួយឲ្យមនុស្សមួយចំនួនអាចគិតពិចារណាអំពី របៀបដែលព្រះយេស៊ូបំភ្លឺជីវិតផ្ទាល់ខ្លួន។

នៅក្នុងអត្ថបទទីមួយ យើងបានឃើញអំពីរបៀបដែលព្រះជាម្ចាស់ ណែនាំឲ្យយើងធ្វើជាសាវ័ករបស់ព្រះអង្គយ៉ាងច្បាស់លាស់។ អត្ថបទទីមួយ គឺនិយាយអំពីព្រះបាទដាវីឌដែលជិតដល់ថ្ងៃសោយទិវង្គត ជិតដល់ថ្ងៃលាចាកផែនដីនេះ នៅពេលនោះគាត់និយាយជាមួយកូនរបស់គាត់ គឺសាឡូម៉ូន ដោយបានបំភ្លឺអំពីចំណុចពីរដ៏សំខាន់៖ "**ចូរមានចិត្តស្មោះត្រង់នឹងព្រះអម្ចាស់ជាព្រះរបស់បុត្រ។ ចូរប្រព្រឹត្តតាមព្រះហឫទ័យរបស់ព្រះអង្គជានិច្ច នៅក្នុងគ្រប់កិច្ចការដែលបុត្រធ្វើ និងនៅគ្រប់ទីកន្លែងដែលបុត្រទៅ**"។ យើងទុកនេះ សម្រាប់ជីវិតរបស់យើងដែលធ្វើដំណើរជាមួយព្រះយេស៊ូគឺ៖

ទីមួយ **ឲ្យយើងមានចិត្តស្មោះនឹងព្រះអម្ចាស់** នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ មិនមែនសម្រាប់តែលោកសាឡូម៉ូន ប៉ុន្តែសម្រាប់យើងនៅថ្ងៃនេះ។ សម្រាប់យើងប្រចាំថ្ងៃ យើងជាអ្នកបួសក៏ដោយ យើងជាគ្រីស្តបរិស័ទធម្មតាក៏ដោយ យើងធ្វើយ៉ាងម៉េចដើម្បីមានចិត្តស្មោះត្រង់ចំពោះព្រះជាម្ចាស់។ ព្រះជាម្ចាស់ មានព្រះហឫទ័យស្មោះចំពោះយើង ព្រះជាម្ចាស់មិនដែលចោលយើង ប៉ុន្តែជីវិតរបស់យើងជាជីវិតដែលត្រូវតែកែប្រែចិត្តគំនិតថែម

ទៀត និងថែមទៀត ដូចក្រុមគ្រីស្តទូតពីដើម នៅពេលព្រះយេស៊ូបានឲ្យគេធ្វើដំណើរពីរនាក់ៗ ព្រះយេស៊ូបានណែនាំឲ្យគេចេញដើម្បីប្រកាសប្រាប់មនុស្សម្នាប្រែចិត្តគំនិត។ ប៉ុន្តែមុនគិតអំពីមនុស្សម្នា ឲ្យគិតអំពីយើងផ្ទាល់ដើម្បីកែប្រែចិត្តគំនិត ដើម្បីមានចិត្តស្មោះត្រង់ចំពោះព្រះជាម្ចាស់។

ទីពីរ **ឲ្យយើងប្រព្រឹត្តតាមព្រះហឫទ័យរបស់ព្រះអង្គ** នៅក្នុងគ្រប់កិច្ចការដែលបុត្រធ្វើ និងនៅគ្រប់ទីកន្លែងដែលបុត្រទៅ តាមពិតនៅពេលយើងបានជ្រើសរើសជីវិតជាសាវ័ករបស់ព្រះជាម្ចាស់ នៅពេលយើងឆ្លើយតបព្រះជាម្ចាស់ យើងមិនអាចចែកជីវិតរបស់យើងជាពីរ ដោយជួនកាលយើងនៅជាមួយព្រះជាម្ចាស់ ជួនកាលយើងនៅជាមួយលោកីយ៍ ជួនកាលយើងនៅជាមួយព្រះជាម្ចាស់ ជួនកាលយើងភ្លេចព្រះជាម្ចាស់អស់ហើយ។ នៅពេលនោះ បាននិយាយច្បាស់នៅក្នុងគ្រប់កិច្ចការ ប៉ុន្តែមិនមែនត្រឹមតែនៅក្នុងគ្រប់កិច្ចការទៀត គឺនៅគ្រប់កន្លែងដែលយើងនៅ។ តាមពិតជីវិតរបស់យើង នៅពេលយើងចាប់ផ្ដើមធ្វើដំណើរជាមួយព្រះជាម្ចាស់យ៉ាងពិតៗ ធ្វើយ៉ាងម៉េចដើម្បីមានចិត្តស្មោះ? និងចិត្តស្មោះនេះត្រូវការបង្ហាញយ៉ាងជាក់ស្តែងនៅក្នុងការងាររបស់យើងប្រចាំថ្ងៃ នៅគ្រប់ទីកន្លែងដែលយើងរស់នៅ ដើម្បីឲ្យយើងភ្ជាប់ជាមួយព្រះជាម្ចាស់ និងដើម្បីឲ្យយើងរស់នៅជាមួយព្រះជាម្ចាស់តាមព្រះហឫទ័យរបស់ព្រះអង្គ។ នៅក្នុងគ្រប់ទីកន្លែងយើងធ្វើយ៉ាងម៉េចដើម្បីទៅជាសាក្សី? យើងជានិស្សិតទេវ យើងជាឪពុកម្តាយ យើងជាលោកតាលោកយាយ យើងជាបងស្រី យើងទទួលខុសត្រូវយ៉ាងខ្ពស់ដើម្បីណែនាំឲ្យយុវជន ឲ្យកូនក្មេងចាប់ផ្តើមគិតអំពីជីវិតជាអ្នកបួស។ ប៉ុន្តែ ដើម្បីចាប់ផ្ដើមគិតឲ្យយើងទៅជាគំរូសម្រាប់គេ។ ឲ្យយើងជាគំរូដើម្បីឲ្យយើងមុនគេបង្អស់ មុនប្រកាសថា "សូមកែប្រែចិត្តគំនិតទៅ!" ឲ្យយើងកែប្រែចិត្តគំនិត។ ឲ្យយើងកែប្រែចិត្តគំនិត ដើម្បីរស់នៅតាមរបៀបដែលព្រះជាម្ចាស់បានណែនាំ។ បន្ទាប់មកយើងឃើញបេសកកម្មដែលព្រះយេស៊ូបានឲ្យទៅក្រុមគ្រីស្តទូតដំបូងបង្អស់ អ្វីដែលជាសំខាន់គឺមូលដ្ឋាននៃការប្រកាសដំណឹងល្អគឺៈ

**ទីមួយ** ឲ្យគេបានដេញអារក្សជាច្រើន ចេញពីមនុស្សព្រមទាំងចាក់ប្រេងលើអ្នកជំងឺច្រើននាក់ដើម្បីប្រោសឲ្យគេបានជាសះស្បើយ។ នេះជាបេសកកម្មដែលព្រះយេស៊ូ ឲ្យទៅក្រុមគ្រីស្តទូតពីដើម។ របៀបដែលយើងត្រូវប្រកាសដំណឹងល្អ របៀបដែលយើងរស់នៅយើងដើរតាមសម័យបច្ចុប្បន្ននេះ ក៏ប៉ុន្តែយើងមានតួនាទីដដែលៗ និងបេសកកម្មរបស់យើងអត់បានដូរទេ។ យើងនៅទីនេះ ដើម្បីណែនាំឲ្យមនុស្សរកឃើញផ្លូវយ៉ាងត្រឹមត្រូវនៅក្នុងជីវិតគេ នៅតាមរូបកាយ នៅតាមវិញ្ញាណ និងនៅតាមផ្លូវចិត្ត នេះជាតួនាទីរបស់យើង។

ខ្ញុំជឿថា នៅបច្ចុប្បន្ននេះប្រហែលខ្លាំងជាង២០០០ឆ្នាំមុនទៀត ដោយសារ២០០០ឆ្នាំមុន ប្រហែលនៅពេលព្រះយេស៊ូប្រកាសដំណឹងល្អទៅដល់សាសនាយូដា ប្រជាជនច្រើនគេទៅធម្មសាលារៀងរាល់ថ្ងៃសប្បែត។ គេគោរពបុណ្យតាមសាសនាយ៉ាងច្បាស់លាស់ គេគោរពបុណ្យសម្តែងព្រះអង្គទៅវិហារយេរូសាឡឹម គេគោរពខ្លាំងណាស់។ ប៉ុន្តែសម័យនេះ ដោយសារសម័យអភិវឌ្ឍន៍ យើងមានឱកាសយ៉ាងច្រើន យើងមានផ្លូវយ៉ាងច្រើន ដែលណែនាំឲ្យយើងទៅយ៉ាងឆ្ងាយពីសាសនារបស់យើង ពីការអធិដ្ឋានជាប្រចាំ ស្តាប់ព្រះបន្ទូលជាប្រចាំ យើងមិនឃើញខ្វះដើម្បីវង្វេងផ្លូវ។ ប៉ុន្តែបេសកកម្មរបស់យើងដដែល ណែនាំឲ្យមនុស្ស ណែនាំឲ្យបងប្អូនឯទៀតៗមានគោលដៅយ៉ាងច្បាស់នៅក្នុងជីវិត ដើម្បីចិញ្ចឹមទាំងរូបកាយ ទាំងវិញ្ញាណ ទាំងចិត្ត។ នេះជាតួនាទីដែលយើងទទួលជាសាវ័ក ជាគ្រីស្តទូត ជាបូជាចារ្យ ជានិស្សិតទេវ ជាបងស្រី ជាគ្រីស្តបរិស័ទ។ អាចនិយាយថា បេសកកម្មដែលព្រះយេស៊ូឲ្យពីដើមដូចជាអត់មានហួសសម័យ គឺបច្ចុប្បន្ននេះដដែលៗ ប៉ុន្តែនៅក្នុងបរិយាកាសថ្មី នៅក្នុងពិភពថ្មី។ ជាពិសេសនៅក្នុងសង្គមរបស់យើងដែលកំពុងអភិវឌ្ឍន៍ ដែលកំពុងរីកចម្រើនយ៉ាងលឿនមែនទែន តើយើងធ្វើយ៉ាងម៉េចដើម្បីឲ្យយើងទៅដល់អ្វីដែលសំខាន់បំផុត មិនតែចិញ្ចឹមមនុស្សដើម្បីឲ្យយើងសប្បាយនៅក្នុងជីវិតមួយភ្លែតៗ ប៉ុន្តែចិញ្ចឹមចិត្តគំនិតដើម្បីទទួលការសង្គ្រោះ និងការសង្គ្រោះមានន័យថាដើម្បីទទួលជីវិតអស់កល្បជានិច្ច។ ពេលយើងនិយាយពីជីវិតអស់កល្បជានិច្ច យើងធ្វើយ៉ាងម៉េចដើម្បីជម្រះចិត្តគំនិតរបស់យើង ដើម្បីសង្គ្រោះមនុស្សទាំងអស់។ នេះជាតួនាទីដែលយើងបានទទួល។ នៅក្នុងព្រះសហគមន៍ជាបូជាចារ្យ ជាអ្នកដែលថ្វាយសក្ការបូជា ជាគ្រូគង្វាលដែលណែនាំគ្រីស្តបរិស័ទ និងណែនាំបងប្អូនឯទៀតៗដើម្បីរកឃើញផ្លូវនៅក្នុងជីវិត និងដើម្បីរកឃើញសេចក្តីសុខ។ ព្រះយេស៊ូបានបង្ហាញផ្លូវឲ្យយើងតាមរយៈក្រុមគ្រីស្តទូតពីដើម ព្រះយេស៊ូបន្តបង្ហាញផ្លូវឲ្យយើង ឲ្យយើងធ្វើយ៉ាងម៉េចដើម្បីបន្តណែនាំមនុស្សយ៉ាងច្រើនទទួលជីវិតថ្មី ដោយសារជំនឿរបស់យើងរឹងមាំ កុំឲ្យយើងភ្លេចនៅពេលដែលក្រុមគ្រីស្តទូតបានត្រលប់មកវិញ ពីការធ្វើដំណើរនៅថ្ងៃដែលព្រះយេស៊ូបានចាត់គេដំបូង គេត្រលប់មកវិញនិងថា **"យើងពិបាកក្នុងការដេញអារក្សអ្នកតា យើងពិបាកដើម្បីណែនាំឲ្យអ្នកជំងឺជាសះស្បើយ"**។ ព្រះយេស៊ូបានឆ្លើយថា ដោយសារខ្វះជំនឿ ជំនឿតិចពេក ដូច្នេះយើងណែនាំឲ្យអ្នកដទៃជាសះស្បើយមិនបាន ណែនាំឲ្យបងប្អូនឯទៀតៗមានជីវិតថ្មីមិនបាន។ នេះជាបញ្ហាដែលក្រុមគ្រីស្តទូតបានជួបពីដំបូង និងជាបញ្ហាដែលយើងជួបដែរ ដោយសារប៉ុន្មានដងប៉ុន្មានសារ យើងនៅជាមួយអ្នកជំងឺ នៅជាមួយកូនក្មេងម្នាក់ដែលស្លាប់ ហើយយើងចង់ធ្វើដូចព្រះយេស៊ូឲ្យគេមានជីវិតឡើងវិញ យើងចង់ឲ្យអ្នកជំងឺនេះមានកម្លាំងជាសះស្បើយឆាប់ៗ ប៉ុន្តែ

យើង ធ្វើដូចព្រះយេស៊ូមិនបានដោយសារជំនឿរបស់យើងនៅស្ទើរ។ នៅពេលនោះព្រះយេស៊ូបានបំភ្លឺក្រុមគ្រីស្តទូតៈ **ប្រសិនបើយើងមានជំនឿយ៉ាងតិចបំផុត យើងអាចណែនាំឲ្យដើមឈើដែលនៅកន្លែងហ្នឹងទៅកន្លែងមួយទៀត**។ នេះជាជំនឿដែលព្រះយេស៊ូចង់ឲ្យយើងមាន។ ប៉ុន្តែដើម្បីឲ្យយើងមានជំនឿដល់កម្រិតនេះ យើងត្រូវតែបន្តកែប្រែចិត្តគំនិតផ្ទាល់ខ្លួន មិនមែនត្រឹមទេប្រកាស "សូមកែប្រែចិត្តគំនិត និងជឿលើដំណឹងល្អចុះ" ប៉ុន្តែយើងត្រូវការចាប់ផ្តើមពីយើងសិនដើម្បីទទួលជីវិតថ្មី ដើម្បីមានសមត្ថភាព និងមានកម្លាំងកាយកម្លាំងចិត្ត ដើម្បីណែនាំបងប្អូនឯទៀតៗទទួលជីវិតថ្មី តាមរូបកាយ តាមវិញ្ញាណ និងតាមផ្លូវចិត្ត។

ដូច្នេះថ្ងៃនេះ យើងអធិដ្ឋានថែមទៀតសម្រាប់យើងទាំងអស់ ដែលទទួលខុសត្រូវយ៉ាងខ្ពស់នៅក្នុងព្រះសហគមន៍ ដែលជាគ្រីស្តទូតផង ដែលជាសាវ័កផង ដែលណែនាំឲ្យមនុស្សជាពិសេសយុវជន យុវនារី ឲ្យស្តាប់ព្រះសបន្ទូលរបស់ព្រះជាម្ចាស់ និងសុខចិត្តលះបង់ចោលតាមព្រះបន្ទូលហ្នឹង ដើម្បីទទួលសេចក្តីសុខរួមជាមួយព្រះយេស៊ូ។ អាម៉ែន៕